ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០២២

នៅក្នុងខែមិថុនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារតាមដានការអនុវត្តច្បាប់**

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីសកម្មភាពការងារ រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ពុទ្ធសាសនបណ្ឌិត្យ នៅរាជធានីភ្នំពេញ។

**២- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** និង**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា** អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារទីចាត់ការថ្មីចំនួន១ខ្នង កម្ពស់២ជាន់ មាន១៥បន្ទប់ ដែលជាអំណោយរបស់លោកឧកញ៉ា **លៀង ផន** និងលោកជំទាវ **ឈឹម ណារី** ស្ថិតនៅក្នុងបរិវេណវិទ្យាល័យ ជា ស៊ីម ជ្រោយចង្វារ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- បានផ្តល់សេវា និងអមដំណើរ **ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ព្រះវិហារវត្តលុម្ពិនីសាលវ័ននារាម ហៅវត្តអូរសោម ស្ថិតនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

- បានផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមពិធីខួបលើកទី៤៥ ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរលំរបបប្រល័យពូជសាសន៍ ប៉ុល ពត (២០ មិថុនា ១៩៧៧-២០ មិថុនា ២០២២) និងសម្ពោធសមិទ្ធផលនានា ក្រោមអធិបតីភាព**សម្តេចអគ្គមហាសេនាបតីតេជោ**



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443, ទូរសារ: (855 23) 211 446, E-mail: oumsarith_sgsenate@gmail.com, oumsarith_sgsenate@yahoo.com

**ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ផាម មិញ ជិញ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅខេត្តត្បូងឃ្មុំ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ដើម្បីជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ-សង្កាត់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ភោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេសអំពាវនាវដល់ប្រជាពលរដ្ឋឱ្យទៅចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឱ្យបានគ្រប់គ្នានៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង ចំនួន១៨៣លើក

- បានទទួលពាក្យបណ្តឹងចំនួន០៤ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន០៥ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធ ចំនួន០១ករណី កំពុងពិនិត្យសិក្សាចំនួន០២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៧ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៥ករណី ធ្វើលិខិតរំលឹកជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន ០១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន ០២ករណី

- បានធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ជូនសាស្ត្រាចារ្យ និង និស្សិតនៃសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប និងវិទ្យាស្ថានវ៉ាន់ដា ចំនួន២៩៨នាក់

- លេខាធិការដ្ឋានសមាគមសង្គហៈនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បាននាំយកបច្ច័យចំនួន ២លានរៀល ប្រគេនព្រះភិក្ខុ សច្ចកល្យាណោ **យន់ លីអង** មានអាពាធបេះដូង គង់នៅវត្តទំពូង-អង្គចំរើនមានជ័យ ខេត្តកំពង់ស្ពឺ

- បានចាត់ចែងបញ្ជូនសារលិខិតរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ទូលថ្វាយ**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងឱកាសនៃព្រះរាជពិធីចម្រើនព្រះជន្ម និង សារលិខិតជូនពរឥស្សរជនជាន់ខ្ពស់ តាមក្រសួង និងស្ថាប័ននានាក្នុងឱកាសចម្រើនជន្មាយុ

- បានរៀបចំ និងផ្ញើសាររំលែកទុក្ខជូនគ្រួសារសពមន្ត្រីជាន់ខ្ពស់ចំនួន០១លើក

- បានផលិត និងផ្សព្វផ្សាយទស្សនាវដ្ដីប្រចាំខែមិថុនា ឆ្នាំ២០២២ ចំនួន៨០០ក្បាល។

**៣- មុខងារសហប្រតិបត្តិការអន្តរជាតិ**

- បានរៀបចំទីកន្លែង និងផ្ដល់សេវាក្នុងពិធីជំនួបសម្ដែងការគួរសម និងសវនាការជូន ***សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា*** ជាមួយលោកជំទាវ Dalila Yasmin AMRI SUED ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋវ៉ាន់ដា ប្រចាំព្រះរាជាណាចក្រកម្ពុជា, និងឯកឧត្ដមបណ្ឌិត ***មហាំម៉ាត់ អាប់ឌុលការីមអាល់អ៊ីសា*** (MOHAMMA ABDULKARIM AALISSA) អគ្គលេខាធិការសម្ព័ន្ធពិភពអ៊ីស្លាម (MWL/RABITA) ប្រធានសមាគមបញ្ញវ័ន្តអ៊ីស្លាម

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានា តាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់ រួមមាន៖ កិច្ចប្រជុំប្រចាំឆ្នាំរបស់ AIPACODD លើកទី៥ នៃក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ាស្ដីពីគ្រឿងញៀន, កិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមអ្នកនយោបាយអាយប៉ា លើកទី១៣ ក្រោមប្រធានបទ "ការអនុវត្តលើសេចក្ដីសម្រេចនៃមហាសន្និបាតអាយប៉ាលើកទី៤២ និងកិច្ចសហប្រតិបត្តិការលើសេដ្ឋកិច្ចឌីជីថលក្នុងអាស៊ានក្រោយវិបត្តិកូវីដ-១៩", កិច្ចប្រជុំក្រុមការងារ (APF) ដើម្បីត្រៀមចូលរួមមហាសន្និបាតលើកទី៤៧ នៃសភាប្រើភាសាបារាំង នៅទីក្រុងហ្គីហ្គាលី ប្រទេសវ៉ាន់ដា, កិច្ចប្រជុំគណៈកម្មការកិច្ចការសភា(APF) ក្រោមអធិបតីភាព ឯកឧត្ដម Joël Godin ប្រធានគណៈកម្មការកិច្ចការសភា (APF) នៅសភាសហព័ន្ធវ៉ាល់ឡូនី ព្រុចសែល ប្រទេសបែលហ្ស៊ិក, និងកិច្ចប្រជុំត្រៀមរៀបចំមហាសន្និបាតអាយប៉ាលើកទី៤៣ ដែលសភាកម្ពុជាធ្វើជាម្ចាស់ផ្ទះ

- ឯកឧត្ដម ***អ៊ុំ សារិទ្ធ*** អគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូត វិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋឆែក ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបពិភាក្សាការងារ អំពីការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងស្ថានទូតនៃសាធារណរដ្ឋឆែក ព្រមទាំងបានអនុញ្ញាតឱ្យអតីតកម្មសិក្សាការីដែលបានធ្វើកម្មសិក្សានៅការិយាល័យហ្វ្រង់កូហ្វូនី ចូលជួបសម្ដែងការគួរសម

- បានរៀបចំពិធីប្រគល់ និងទទួលជំនួយសម្ភារវេជ្ជសាស្ត្រពីអង្គការចែករំលែកសង្គ្រោះអាយុជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ព្រមទាំងបានរៀបចំពិធីប្រគល់ឱសថ និងបរិក្ខារពេទ្យ ជូនដល់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យគន្ធបុប្ផា(ភ្នំពេញ) និងក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា ខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតចិន, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ទីស្ដីការគណៈរដ្ឋមន្ត្រី, អង្គការមូលនិធិអាស៊ី, អង្គការតម្លាភាពកម្ពុជា

(TI Cambodia), សាលាភូមិន្ទរដ្ឋបាល, មជ្ឈមណ្ឌលសភាអាស៊ី(PCA), វិទ្យាស្ថានជាតិស្ថិតិ(NIS), ភ្នាក់ងារសព្ទមព័ត៌មានជាតិ(NIA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, ក្រុមហ៊ុនHUAWEI និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៤- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានសហការ និងសម្របសម្រួលការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩(ដូសទី៥) ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា, ថ្នាក់ដឹកនាំ សមាជិក សមាជិកាក្រុមប្រឹក្សាជម្មនុញ្ញ, ទីប្រឹក្សារបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា, ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រួមទាំងក្រុមគ្រួសារ ប្រកបដោយជោគជ័យ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនជូនក្រុមគ្រូពេទ្យមកពីមន្ទីរពេទ្យកាល់ម៉ែត
- បានប្រជុំពិនិត្យ និងពិភាក្សាស្តីពី កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានប្រជុំពិនិត្យផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (ឆ្នាំ២០២៣-២០២៥) របស់ព្រឹទ្ធសភា និងគម្រោងថវិកាឆ្នាំ២០២៣ របស់ព្រឹទ្ធសភា
- បានប្រជុំស្តីពី ការងារគ្រប់គ្រងបុគ្គលិកនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រជុំពិនិត្យលើរបាយការណ៍សវនកម្មផ្ទៃក្នុង
- បានប្រជុំការងារជាមួយអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ
- បានប្រជុំពិនិត្យ និងកែសម្រួលវីដេអូចំនួន០២ខ្សែ ស្តីពីសមិទ្ធផលនានា ដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិនដល់ព្រឹទ្ធសភាកម្ពុជា និងស្តីពីបណ្ណាល័យព្រឹទ្ធសភា
- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មីៗ

**៤.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ**

- បានទទួលលិខិតចូលចំនួន៣៧៣ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣២៥ច្បាប់
- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង
- បានបើកប្រាក់បៀវត្សប្រចាំខែមិថុនា ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំ

ខែមិថុនា ឆ្នាំ២០២២

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន០៩ច្បាប់ និងធ្វើប័ណ្ណសម្គាល់ខ្លួនចំនួន០៦ប័ណ្ណ

- បានបើកវគ្គបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសចំនួន០១វគ្គ មានសិក្ខាកាមចូលរួមចំនួន១១០នាក់, សិក្ខាសាលាក្នុងប្រទេសចំនួន០១លើក មានសិក្ខាកាមចូលរួមចំនួន០២នាក់

- បានធ្វើស្លាកប៉ាណូឡូហ្គោព្រឹទ្ធសភា នៅច្រកចេញ-ចូល P2

- បានជួសជុលប្រព័ន្ធអគ្គិសនី សម្អាតដំបូលតាមអគារ និងសាលប្រជុំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្តូរកម្រាលព្រំ ប្តូរអ្ញូតទ្វារអាលុយមីញ៉ូម និងដាក់កែងអ្ញូតទ្វារដែក នៅអគារ D E F នាយកដ្ឋានព័ត៌មានវិទ្យា និងនាយកដ្ឋានផែនការ និងសរុប

- បានរៀបចំជួសជុលថ្មម៉ាប និងប្តូរប្រព័ន្ធសង្គ្រោះពេលជាប់គាំងជណ្តើរយន្តនៅអគារថ្នាក់ដឹកនាំព្រឹទ្ធសភាទាំងបី

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន០៨លើក

- បានតុបតែងលម្អស្រះចិញ្ចឹមត្រីក្នុងបរិវេណអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក, ត្រួតពិនិត្យសត្វកណ្តៀរ, ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៤០គ្រឿង/លើក

- បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើងក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន៣៧លើក

- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ ទូលថ្វាយ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ ព្រមទាំងបានផ្សព្វផ្សាយ

ទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា

- បានធ្វើរបាយការណ៍ស្តីពី ការពិនិត្យ និងតាមដានការអនុវត្តផែនការប្រតិបត្តិរបស់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានទាំង៩ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី២ ឆ្នាំ២០២២។

**៤.២-ការងារសេវាច្បាប់៖**

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន៣២៦ច្បាប់

- បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន០៦ច្បាប់

- បន្តចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ

- បានធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០២២-២០២៤)។

**៤.៣-ការងារស្រាវជ្រាវ៖**

- កំពុងសិក្សាស្រាវជ្រាវ និងចងក្រងឯកសារចំនួន១៣ប្រធានបទ

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៦១អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមិថុនា ឆ្នាំ២០២២ ចំនួន០៤ច្បាប់។

**៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួច

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេក-វិទ្យាព័ត៌មានចំនួន១៨៦គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាចំនួន ៩៩ប្រធានបទ

- បានបន្តបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ និងIpad ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥៨គ្រឿង

- បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន១០៣ក្បាល ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ បញ្ជូនសៀវភៅទៅសេវាអ្នកអាន បិទប័ណ្ណខ្ចី និងសងសៀវភៅចំនួន៨៦ក្បាល

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន**២០លើក** និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១៨លើក

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Chanel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន ១,៣៧០ប្រធានបទ

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន។

**៤.៥-ការងារពិធីការៈ**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៥លើក

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១១ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមិថុនា ឆ្នាំ២០២២ ចំនួន០១ច្បាប់

- បានកសាងជំនួយស្មារតី សុន្ទរកថា និងបកប្រែឯកសារនានា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន ០៧ច្បាប់។

**៤.៦-ការងារអគ្គាធិការដ្ឋានៈ**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា ឆ្នាំ២០២២ ចំនួន១៩លើក

- បានជួបប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើរបាយការណ៍ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារនៃអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យជាក់ស្តែងតាមនាយកដ្ឋាន ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលអង្គភាព

ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋាន រៀងរាល់ថ្ងៃ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃចំនួន២២លើក **ប្រចាំសប្តាហ៍** ចំនួន០២លើក និងប្រចាំខែមិថុនា ឆ្នាំ២០២២

- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែមិថុនា ឆ្នាំ២០២២

- បានធ្វើរបាយការណ៍ស្តីពី ការស្រាវជ្រាវត្រួតពិនិត្យអំពីការអនុវត្តការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែមិថុនា ឆ្នាំ២០២២។

**II-លទ្ធផលការងារគាំទ្រលើមុខងារធានា៥ះ**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១២០ច្បាប់

- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព ធ្វើហ្វុងអក្សរ និងចងបដា ពាក្យស្លោកចំនួន ១២លើក

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៩ច្បាប់ ស្មើនឹង២៨នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៥ច្បាប់ ស្មើនឹង០៥នាក់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២៨៥លើក

- បានដោះស្រាយថវិកា សម្រាប់រៀបចំដង្វាយថ្វាយ**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន៨១សំណើ

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៣៩លើក មានអ្នកចូលរួមចំនួន១,៧២៧នាក់

- បានសួរសុខទុក្ខមន្ត្រីរាជការមានជំងឺ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន ០៦នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២១០លីត្រ ជូនអង្គភាពចំណុះអគ្គ-

លេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន៤,៩៧៣ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន២៨ក្បាល អស់ក្រដាសចំនួន២៨,៣៣៤សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន១៨២លើក ស្មើនឹង២៧១នាក់

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន០៩លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន៨២លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន២០លើកៗ

**II-ទិសដៅការងារខែកក្កដា ឆ្នាំ២០២២**

+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ

+បន្តប្រឈមការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន

+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+លើកកម្ពស់សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេកវិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

**-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៩ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ**

+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

+ទ្រទ្រង់ដំណើរឆ្ពោះទៅកាន់មូលដ្ឋានរបស់សមាជិកព្រឹទ្ធសភា ក្នុងរយៈពេលវិស្សមកាល

+បង្កើនគុណភាព និងប្រសិទ្ធភាពផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា **ឱ្យបានល្អប្រសើរ** និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះទៅមូលដ្ឋាន និងជួបសវនាការជាមួយក្រសួង ស្ថាប័ននានា

- ត្រៀមសហការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញនីតិកាលទី៤។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន និងអាជ្ញាធរដែនដី ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំជូនគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញចូលរួមមហាសន្និបាតលើកទី៤៧ នៃសភាប្រើភាសាបារាំង នៅប្រទេសរ៉ាន់ដា

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩

-ជំរុញកម្មវិធីបណ្តុះបណ្តាលមន្ត្រីក្នុង និងក្រៅប្រទេស តាមកម្មវិធីសហប្រតិបត្តិការជាមួយភាគីជាមិត្ត (PCA, AVI) និងដៃគូផ្សេងៗទៀត

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ (PCA, ITECH, MFE, **AIPA**, APF) និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មានៗ

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ការត្រៀមការពារគម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២៣ ក្នុងកម្រិតបច្ចេកទេស និងកម្រិតនយោបាយ

-ការត្រៀមរបាយការណ៍ទូទាត់ថវិកាសម្រាប់ឆមាសទី១ ឆ្នាំ២០២២ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងការអនុវត្តថវិកាសម្រាប់ឆមាសទី២ ឆ្នាំ២០២២

-បន្តតាមដាន និងសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គម្រោងស្នើកសាងអគារថ្មី២ខ្នង និងការស្វែងរកជំនួយពីរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ និងការស្នើសុំឥណទានបន្ថែមពីរាជរដ្ឋាភិបាល

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែកក្កដា ឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា

-ការត្រៀមរៀបចំបែបបទដំឡើងប្រាក់បំណាច់មុខងារដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ឆ្នាំ២០២៣

-បន្តវិចារណកម្មថវិកា៖ សន្សំសំចៃ និងអាទិភាពចំពោះតែការងារចាំបាច់បន្ទាន់ និងប្រញាប់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-កែលម្អបរិស្ថាន និងអនុវត្តការងារជួសជុលផ្សេងៗក្នុងករណីចាំបាច់ ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ អនាម័យ និងវិន័យការងារ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តម្រូវការ និងការប្រឈម

-ត្រៀមរៀបចំផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥របស់ព្រឹទ្ធសភា

-ត្រៀមធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា លើកកម្ពស់សមត្ថភាព

ដឹកនាំ និងគ្រប់គ្រងគ្រប់កម្រិត គ្រប់វិស័យ ពង្រឹងពង្រីកសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងសាធារណៈ:

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ព្រមទាំងការចូលរួមវគ្គផ្សេងៗ រៀបចំដោយសភានៃប្រទេសជាមិត្ត (ឥណ្ឌា...)

-បន្តរៀបចំផលិតវីដេអូស្តីពី បណ្ណាល័យព្រឹទ្ធសភា និងវីដេអូសមិទ្ធផលនានា ដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន

-រៀបចំសៀវភៅទិនានុលេខន៍ព្រឹទ្ធសភាឆ្នាំ២០២៣

-ត្រៀមរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពី នវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈ សវនកម្មផ្ទៃក្នុង និងអធិការកិច្ចហិរញ្ញវត្ថុ។

IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែមិថុនានេះ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតទូទាំងប្រទេស បានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ យ៉ាងច្រើនកុះករ នៅតាមមូលដ្ឋានរៀងៗខ្លួន។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ក្នុងការផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា លើមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ដោយបានចុះបំពេញបេសកកម្ម ជួបសវនាការការងារជាមួយក្រសួង និងស្ថាប័ននានា ព្រមទាំងអមដំណើរសមាជិកព្រឹទ្ធសភា ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ព្រមទាំងផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសណែនាំប្រជាពលរដ្ឋឱ្យទៅចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ (ដូសជំរុញ) ឱ្យបានគ្រប់ៗគ្នា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរជូនថ្នាក់ដឹកនាំ និង

សមាជិកព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងជួបពិភាក្សាការងារជាមួយគណៈប្រតិភូអន្តរជាតិ ក្នុងការបង្កើនទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការបានកាន់តែល្អប្រសើរជាលំដាប់។

មន្ត្រីរាជការទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធាន និងការណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងល្អប្រសើរ។

ថ្ងៃអង្គារ ៧កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២

**អគ្គលេខាធិការ**

អ៊ុំ សារិទ្ធ